Student/Registration Number | | | | | | | | | | |

Centre Number | | | | | | |

2011 PUBLIC EXAMINATION

Khmer

Continuers Level

Monday 24 October: 2 p.m. Eastern Standard Time

Reading Time: 10 minutes
Writing Time: 2 hours and 50 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

Section 1: Listening and Responding (30 marks)

Instructions to Students

1. Allow approximately 50 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet in blue or black ink or ball-point pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2011

www.theallpapers.com

Part A (Questions 1 to 4)
(20 marks)

When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

You will hear FOUR texts. Each text will be played twice. There will be a short break between the first and second playings in which you may make notes.

Listen carefully to each text and then answer the questions in ENGLISH.

Marks | You may make notes in this space.

Text 1

Vocabulary
ឋានមនោរម្យធម្មជាតិ— natural wonderland

1. (a) What threats does Bokor National Park face? **2**

_____

_____

_____

_____

_____

(b) Why is Bokor National Park called a paradise and a natural wonderland? **2**

_____

_____

_____

_____

_____

_____

_____

_____

www.theallpapers.com

Marks

You may make notes in this space.

Text 2

2. What does the conversation tell us about the relationship between Sinoun and her father? Support your answer with evidence from the text. **5**

www.theallpapers.com

Marks

You may make notes in this space.

Text 3

3. (a) What is Syna's request to his older sister, Chantha? **1**

(b) Explain Chantha's response to Syna's request. **3**

(c) How does Syna's language reflect his emotions? **2**

www.theallpapers.com

Marks

You may make notes in this space.

Text 4

4. (a) How would you describe Lakhon Bassac? **3**

(b) Explain why Lakhon Bassac has declined in popularity. **2**

www.theallpapers.com

Part B (Questions 5 to 6)
(10 marks)

When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:

- *understand general and specific aspects of texts by identifying and analysing information;*
- *convey the information accurately and appropriately.*

You will hear TWO texts, one relating to Question 5 and one relating to Question 6. Each text will be played twice. There will be a short break between the first and second playings in which you may make notes.

Listen carefully to each text and then answer the questions in KHMER.

Marks

You may make notes in this space.

Text 5

5. (a) How appropriate is the style of language used in the text? **1**

តើភាសាដែលគេប្រើក្នុងអត្ថបទសមរម្យយ៉ាងដូចម្តេចដែរ?

_____

_____

(b) Complete the table below by listing the activities at the temple in chronological order. **3**

ចូរបំពេញតារាងខាងក្រោមដោយចុះសកម្មភាពនៅវត្តតាមលំដាប់ពេលវេលា។

Schedule of activities at the temple
កម្មវិធីនៃសកម្មភាពនៅវត្ត

ពេលព្រឹក	ជួបជុំគ្នានៅវត្ត
	ស្តាប់លោកសូត្រមន្ត
	វេរចង្ហាន់និងគ្រឿងសំភារៈនានាប្រគេនដល់ព្រះសង្ឃ
	ទទួលទានអាហារតាមគ្រួសាររៀងៗខ្លួន
ពេលរសៀល	
	លេងល្បែងកំសាន្តប្រជាប្រិយ៍ខ្មែរ

www.theallpapers.com

Marks

You may make notes in this space.

Text 6

6. (a) What is your impression of daily life for Phon's family? Support your answer with evidence from the text. **4**

តើអ្នកមានចំនាប់អារម្មណ៍ទៅលើជីវភាពប្រចាំថ្ងៃរបស់គ្រួសារលោកផុនយ៉ាងណាដែរ? ចូរគាំទ្រចំលើយរបស់អ្នកដោយស្រង់ភស្តុតាងចេញពីអត្ថបទ។

(b) Why is Phon strict? **2**

ហេតុអ្វីបានជាលោកផុនតឹងរឹង?

End of Section 1

www.theallpapers.com

KHMER (CONTINUERS) EXAMINATION 2011

Section 1: Listening and Responding

PART A

Text 1

អស់លោក លោកស្រីជាទីមេត្រី! តទៅនេះយើងខ្ញុំសូមបង្ហាញជូននូវឧទ្យានជាតិដ៏ល្បីល្បាញមួយនៅប្រទេសកម្ពុជាដែលមានឈ្មោះថាបូកគោ។
ចាប់តាំងពីពេលកកើតមកនៅឆ្នាំ១៩៣៣ ឧទ្យានជាតិបូកគោត្រូវបានប្រឈមមុខនឹងការកាប់បំផ្លាញព្រៃឈើរួមនឹងការបរបាញ់សត្វខុសច្បាប់មួយចំនួនយ៉ាងធំគួរសម នៅក្នុងតំបន់រុក្ខជាតិដ៏ខៀវស្រងាត់ដែលនៅជុំវិញឧទ្យានជាតិនេះ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ឧទ្យានជាតិបូកគោនៅតែជាហានសួគ៌មួយរបស់ដំរី ឈ្លូសជាច្រើននិងខ្លាប្រភេទកំរពិសេសខ្លះ។ វាជាហានមនោរម្យធម្មជាតិមួយដែលមានទឹកជ្រោះស្ទឹងនានានិងរុក្ខជាតិកំរប្លែកៗមួយចំនួន។

សូមទូរទស្សនិកជនទាំងអស់កុំភ្លេចទៅទស្សនាឧទ្យានជាតិបូកគោអោយសោះ។

www.theallpapers.com

Text 2

ឪពុក ស៊ីនួន ឆ្នាំនេះម៉ាក់និងប៉ាមានគំរោងនឹងទៅលេងស្រុកខ្មែរ ប៉ុន្តែមុននឹងសំរេចចិត្តថាទៅ ប៉ាចង់ពឹងឯងឯងបន្តិច។

ស៊ីនួន ពេលណាប៉ាអញ្ជើញទៅ? ហើយប៉ាទៅយូរប៉ុណ្ណា?

ឪពុក នៅចុងឆ្នាំក្នុងវិស្សមកាលសាលាចំនួនមួយខែ។ ឯងទៅណាទេពេលហ្នឹង?

ស៊ីនួន ច៎ាសប៉ា! ខ្ញុំគិតទៅលេងពួកម៉ាកខ្ញុំនៅហ្វបាត ប៉ុន្តែបើប៉ាត្រូវការខ្ញុំ ខ្ញុំនឹងមិនទៅទេ។ ចុ៎ះប៉ាចង់អោយខ្ញុំធ្វើអី?

ឪពុក ប៉ាចង់អោយឯងស្រោចស្នូនច្បារយើង មើលថែរក្សាឆ្មា យកសំបុត្រទុក មើលបង់ថ្លៃទឹក ភ្លើង អ្វីៗ ហើយឯងមិនត្រូវនាំមិត្តភក្តិមកលេងផ្ទះច្រើនពេកទេ។ ឯងត្រូវតែរក្សាផ្ទះអោយបានស្អាត។ តើឯងធ្វើអ្វីៗទាំងអស់នេះបានទេ?

ស៊ីនួន បង់ថ្លៃទឹកភ្លើង! ខ្ញុំមិនមានលុយច្រើនទេប៉ា ប៉ុន្តែខ្ញុំសន្យាថានឹងធ្វើអ្វីៗទៀតតាមប៉ាប្រាប់។

ឪពុក កុំព្រួយនឹងប្រាក់កាស ប៉ានឹងទុកលុយអោយឯងគ្រប់គ្រាន់មុននឹងប៉ាទៅ។

ស៊ីនួន អញ្ចឹងមិនអីទេ ខ្ញុំនឹងនៅផ្ទះហើយនឹងធ្វើកិច្ចការទាំងអស់នោះ។

www.theallpapers.com

Text 3

ស៊ីណា បង! តើបងដឹងច្បាស់អំពីប្រវត្តិសាស្ត្រខ្មែរប៉ុនណា?

ចន្ថា គួរសមដែរ។ ប៉ុន្តែម៉េចបានជាឯងចង់ដឹង?

ស៊ីណា ខ្ញុំត្រូវការជំនួយសំរាប់ធ្វើកិច្ចការសាលារបស់ខ្ញុំ។ សូមបងជួយខ្ញុំផងណា៎ ណា៎ ណា៎!

ចន្ថា ឥឡូវណេះសំដីពិរោះដាក់បងណាស់ណា៎។ កាលពីម្សិលមិញ បងពឹងឯងមិនបានទេមែនទេ?

ស៊ីណា បាទមែនបង ប៉ុន្តែនោះមកពីខ្ញុំរវល់ពេក។ ពេលក្រោយខ្ញុំសន្យាថា ស្ពឹក់ដោយក៏ខ្ញុំនឹងធ្វើជូនបងដែរ។

ចន្ថា ពេលនេះបងមិនចង់ជួយឯងទេ ព្រោះបងចង់ដាក់មេរៀនអោយឯងម្តង។

ស៊ីណា ទេ សូមបងកុំធ្វើអញ្ចឹង ខ្ញុំសូមអង្វរ។ នេះជាការសំខាន់សំរាប់ការរៀនសូត្រថ្នាក់ឆ្នាំទី១២របស់ខ្ញុំ។

ចន្ថា ម៉េចបានជាឯងមិនស្រាវជ្រាវខ្លួនឯងរកពត៌មានតាមអ៊ិនធ័រណិត មើលក្នុងទស្សនាវដ្តី រឺក្នុងសារពត៌មានខ្មែរផ្សេងៗ។

ស៊ីណា បាទ ខ្ញុំរកូរចហើយ ប៉ុន្តែវាជិតដល់ពេលខ្ញុំត្រូវអោយគ្រូហើយ។ សូមបងជួយខ្ញុំតែម្តងទៀតទេណា៎ ខ្ញុំសំពះ។

ចន្ថា ទេ បងរវល់ណាស់។ ទៅអោយឆ្ងាយ។

ស៊ីណា អញ្ចឹងក៏បាន មិនអីទេ។ ប៉ុន្តែខ្ញុំនឹងទៅប្រាប់ម៉ាក់និងប៉ាថា បងមិនព្រមជួយធ្វើកិច្ចការសាលាខ្ញុំទេ។

ចន្ថា ទេ! ទេ! ទេ! កុំធ្វើអញ្ចឹង បងសុខចិត្តជួយឯងហើយ។

www.theallpapers.com

Text 4

អ្នកសំភាស ថ្ងៃនេះខ្ញុំនឹងធ្វើការសំភាសជាមួយលោកសានដែលជាចាងហ្វាងល្ខោនបាសាក់ចេនឡា។ ជំរាបសួរលោកគ្រូ។

លោកសាន បាទ ជំរាបសួរ។

អ្នកសំភាស តើលោកចាប់ផ្តើមបង្កើតក្រុមល្ខោនបាសាក់របស់លោកតាំងពីពេលណាមក?

លោកសាន បាទ ក្រុមល្ខោនរបស់ខ្ញុំបានកកើតតាំងពីដើមឆ្នាំ១៩៦៥ម្ល៉េះ។ កាលពីពេលនោះ ល្ខោនជាផ្នែកកំសាន្តដែលគេចូលចិត្តទស្សនាជាងគេបន្ទាប់ពីភាពយន្តមក។

អ្នកសំភាស ហេតុដូចម្តេចបានជាគេអោយឈ្មោះថាល្ខោនបាសាក់?

លោកសាន ល្ខោនប្រភេទនេះមានដើមកំនើតពីតំបន់មួយនៅជាប់ទន្លេបាសាក់ក្នុងខេត្តព្រះត្រពាំង ខ្មែរកម្ពុជាក្រោម។ នេះជាល្ខោនខ្មែរបុរាណមួយប្រភេទ។

អ្នកសំភាស តើល្ខោននេះបានទទួលឥទ្ធិពលពីវប្បធម៌ណាមួយ?

លោកសាន សំលៀកបំពាក់ ការតុបតែងឆាកនិងភ្លេងមានលំនាំដូចល្ខោនចិន។ ប៉ុន្តែក្រុមគ្រួសារស្តេចមានសំលៀកបំពាក់ដូចសំលៀកបំពាក់របស់អ្នករាំរបាំបុរាណខ្មែរដែរ។

អ្នកសំភាស តើល្ខោនបាសាក់សំដែងរឿងអ្វីខ្លះ?

លោកសាន រឿងដែលគេលេងច្រើនជាងគេគឺរឿងរាមកេរ្តិ៍ដែលជារឿងព្រេងរបស់ឥណ្ឌា។ យើងសំដែងរឿងនេះតៗគ្នាជាច្រើនយប់ ហើយរឿងព្រេងបុរាណខ្មែរមួយចំនួនក៏យើងប្រាកដជាលេងដែរ។ ប៉ុន្តែយើងមិនដែលលេងរឿងសម័យទេ។

អ្នកសំភាស តើសំបុត្រចូលមើលលក់ដាច់អស់ទេរាល់យប់?

លោកសាន រាល់យប់ ចំនួនសំបុត្រលក់ដាច់កាន់តែតិចទៅៗ ដោយហេតុតែមានកំនើននៃផ្នែកកំសាន្តដូចជាទូរទស្សន៍ ភាពយន្ត ជាពិសេសភាពយន្តបរទេស វិទ្យុនិងចំរៀងការាអូខេជាដើម។ យើងស្ទើរតែលក់សំបុត្រមិនបានពាក់កណ្តាលផង ដែលជាហេតុធ្វើអោយយើងមិនអាចបង់ប្រាក់ខែថ្លៃអោយតួងកសំខាន់ៗបានទេ ហើយគេក៏នាំគ្នាឈប់លេងបន្តបន្ទាប់គ្នា។

អ្នកសំភាស គួរអោយសោកស្តាយណាស់ ប៉ុន្តែខ្ញុំសូមអរគុណលោកគ្រូដែលបានអនុញ្ញាតអោយខ្ញុំធ្វើការសំភាសជាមួយ។

www.theallpapers.com

PART B

Text 5

អាឡូ!អាឡូ!ជំរាបសួរបាទ។ ថ្ងៃនេះខ្ញុំបាទមានសេចក្តីសោមនស្សរីករាយនឹងជំរាបជូនដល់អស់លោក លោកស្រីទាំងអស់អោយបានជ្រាបថា ក្នុងឆ្នាំនេះយើងមានការរៀបចំពិធីបុណ្យយើងដូចតទៅ៖
នៅវេលាព្រឹកថ្ងៃសៅរ៍ យើងនឹងចាប់ផ្តើមជួបជុំគ្នានៅវត្ត ហើយជាដំបូងយើងចាប់ផ្តើមស្តាប់លោកសូត្រមន្ត រួចរៀបចំពិធីរាប់បាត្រ និងបញ្ចប់ដោយពិធីវេរចង្ហាន់និងគ្រឿងសំភារៈនានាប្រគេនដល់ព្រះសង្ឃ។ បន្ទាប់មកទៀត យើងនឹងចាប់ផ្តើមទទួលទានអាហារតាមគ្រួសាររៀងៗខ្លួន បន្ទាប់ពីព្រះសង្ឃឆាន់រួច។ នៅពេលរសៀលយើងនឹងមានលេងល្បែងកំសាន្តប្រជាប្រិយ៍ខ្មែររៀបចំឡើងដោយក្រុមយុវជនក្រោយពេលការសំដែងរបស់ក្រុមឆៃយ៉ាំក្នុងការអង្គាសប្រាក់សំរាប់ដាក់វត្តរួច។

www.theallpapers.com

Text 6

អ្នកសំភាស ជំរាបសួរលោកពូ។ លោកពូឈ្មោះអី ហើយមានកូនប៉ុន្មាននាក់?

ផុន បាទជំរាបសួរក្មួយ។ ខ្ញុំឈ្មោះផុន។ ខ្ញុំមានកូនប្រាំមួយនាក់។

អ្នកសំភាស តើលោកពូចាប់ផ្តើមប្រកបរបរដាំដំនាំនេះតាំងពីពេលណាមក?

ផុន ពីប្រាំឆ្នាំមុន។

អ្នកសំភាស ហេតុដូចម្តេចបានជាលោកពូសំរេចចិត្តដាំដើមស្រកានាគនេះ?

ផុន ពីព្រោះដើមស្រកានាគនេះវាស្រួលដាំណាស់ ហើយមិនសូវពិបាកថែផង។ ប្រពន្ធខ្ញុំគេអាចមើលថែរក្សាវាបានទោះបីជាគាត់ជាប់រវល់ថែរក្សាកូនង៉ាក៏ដោយ។ សំខាន់ជាងនេះទៅទៀតនោះ ប្រភេទដីនេះវាត្រូវជាមួយនឹងដំនាំនេះណាស់។ ខ្ញុំក៏ធ្វើស្រែដែរ ដើម្បីបង្កើនថវិកាចំនូលថែមទៀត។

អ្នកសំភាស តើកូនចៅដែលជួយធ្វើការលោកពូទេ?

ផុន បាទជួយ លើកលែងតែកូនង៉ាខ្ញុំចេញ ទាំងអស់គ្នាសុទ្ធតែជួយខ្ញុំទាំងអស់ក្រោយពេលមកពីសាលារៀនវិញ សូម្បីតែកូនប្រុសអាយុប្រាំឆ្នាំរបស់ខ្ញុំក៏ជួយដែរ។ វាអាចធ្វើកិច្ចការស្រាលៗ ដូចជាមើលគោ និងដកស្មៅជាដើម។

អ្នកសំភាស លោកពូសំនាងណាស់ដែលមានកូនរបៀបនេះ។

ផុន បាទ ប៉ុន្តែវាស៊ីសងទៅលើឪពុកម្តាយផងដែរ។ ប្រទេសកម្ពុជាឥឡូវណេះខុសប្លែកពីមុនឆ្ងាយណាស់ កាលណោះមិនមានរបស់ផ្តេសផ្តាសដូចជាល្បែងកុំព្យូទ័រ ការអូខេជាដើម។ គ្រួសារយើងត្រូវតែមានការតឹងរឹង ពីព្រោះយើងមិនចង់អោយកូនចៅយើងធ្លាក់ទៅក្នុងរណ្តៅអន្ទាក់ទាំងនោះទេ។

អ្នកសំភាស តើលោកពូមានគំរោងការទៅអនាគតយ៉ាងដូចម្តេចដែរ?

ផុន ខ្ញុំចង់អោយកូនខ្ញុំទាំងអស់បានទទួលការអប់រំដ៏ល្អបំផុត ហើយមានការងារធ្វើក្នុងក្រុមហ៊ុនឯកជនណាមួយ។ ចំនែកខ្ញុំវិញខ្ញុំចង់សង់ផ្ទះមួយអោយស្អាតហើយមានម៉ូតូល្អមួយ។

អ្នកសំភាស សូមអរគុណលោកពូច្រើនណាស់។

www.theallpapers.com

www.theallpapers.com

Student/Registration Number | | | | | | | | | | |

Centre Number | | | | | | |

2011 PUBLIC EXAMINATION

Khmer

Continuers Level

Section 2: Reading and Responding (30 marks)

Instructions to Students

1. Allow approximately 1 hour and 15 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet in blue or black ink or ball-point pen.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2011

www.theallpapers.com

Part A (Questions 7 to 8)
(20 marks)

When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:

- *understand general and/or specific aspects of texts, by, for example, comparing, contrasting, summarising, or evaluating, and convey the information accurately and appropriately.*

7. Read the text and then answer in ENGLISH the questions that follow.

This text cannot be reproduced here for copyright reasons.

www.theallpapers.com

QUESTIONS

Marks

(a) How does the text portray the Royal Ploughing Ceremony? **4**

(b) According to the text, why do many Cambodian people use the help of fortune tellers? **2**

www.theallpapers.com

Marks

(c) What did the royal oxen do after the symbolic ploughing procession this year? **4**

(d) What predictions were made for the year on the basis of what the royal oxen did? **3**

www.theallpapers.com

This page is intentionally blank

www.theallpapers.com

8. Read the text and then answer in ENGLISH the questions that follow.

យុវជនប្រចាំសប្តាហ៍

ក្រោយពេលដែលនាងបានធ្វើជាស្កុតម្នាក់ ហើយនិងជាសិស្សដ៏ចំនានមួយរូបនៅវិទ្យាល័យ កញ្ញាចាន់ សុទ្ធា អាយុ២១ឆ្នាំបានទទួលភ័ព្វសំនាងយ៉ាងខ្ពស់ដោយបានហោះហើរទៅប្រទេសចំនួនប្រាំមួយក្នុងទ្វីបអាស៊ី។ នាងធ្លាប់បានរៀបសំលៀកបំពាក់ដាក់ក្នុងវ៉ាលីចេញទៅបរទេសជាលើកដំបូងកាលពីនាងទើបតែមានអាយុ១៥ឆ្នាំ។

លោកចាន់ សារិនឪពុករបស់នាងសុទ្ធាមានប្រសាសន៍ថា៖"វាជាការអស្ចារ្យនិងរំភើបមែនទែន។ ជាការពិតណាស់ដែលខ្ញុំមានសេចក្តីបារម្ភបន្តិចដែរ ប៉ុន្តែខ្ញុំត្រូវតែបណ្តោយនាងអោយទៅព្រោះខ្ញុំមានទំនុកចិត្តលើនាងទោះបីជានាងនៅមានវ័យក្មេងក៏ដោយ"។

នាងសុទ្ធាមិនខុសប្លែកពីនារីដទៃឡើយ ប៉ុន្តែកាលនៅពីក្មេងនាងជាកុមារម្នាក់ខិលខូច តែអៀនចំពោះមុខចាស់ទុំ។ នាងបាននិយាយថា "ខ្ញុំតែងតែភិតភ័យពេលណាខ្ញុំត្រូវនិយាយជាមួយលោកគ្រូអ្នកគ្រូ។ ប៉ុន្តែក្រោយពេលដែលខ្ញុំបានទទួលអាហារូបករណ៍ទៅសិក្សានៅបរទេស និងបានធ្វើជាស្កុតចំនួនពីរឆ្នាំមក ចរិតរបស់ខ្ញុំបានផ្លាស់ប្តូរទាំងស្រុង គឺខ្ញុំក្លាយជាមនុស្សសុភាពរាបសារ មានសេចក្តីក្លាហានក្នុងការបញ្ចេញយោបល់ និងចេះឈឺឆ្អាលដល់អ្នកដទៃ"។

នាងសុទ្ធាធ្លាប់ជានិស្សិតនៅមហាវិទ្យាល័យច្បាប់ សិក្សាយកបរិញ្ញាប័ត្រខាងហេរញ្ញិកនិងធនាគាររួមជាមួយនិងបរិញ្ញាប័ត្រភាសាអង់គ្លេសនៅវិជ្ជាស្ថានភាសាបរទេស។ នាងបានបញ្ជាក់ថា៖"កាលពីខ្ញុំនៅជាសិស្ស វាមិនមែនជាការងាយស្រួលទេដែលខ្ញុំរៀនយកបរិញ្ញាប័ត្រពីរក្នុងពេលជាមួយគ្នានោះ ជាពិសេសនៅពេលដែលខ្ញុំត្រូវទៅប្រជុំនៅបរទេសម្តងៗ។ នៅពេលដែលខ្ញុំត្រលប់មកពីបរទេសវិញ ខ្ញុំត្រូវចំនាយពេលយ៉ាងច្រើនដើម្បីរៀនតាមគេអោយទាន់នូវអ្វីដែលខ្ញុំបានខកខាន ដោយធ្វើការសូរមិត្តភក្តិនិងរកជំនួយពីសាស្ត្រាចារ្យផងដែរ។"

សព្វថ្ងៃនេះនាងសុទ្ធាបានសំរេចនូវគោលបំនងរបស់នាងដែលនាងប៉ុនប៉ងតាំងពីក្មេងមក ដោយនាងបានទទួលការងារធ្វើក្នុងអង្គការក្រៅរដ្ឋាភិបាលមួយ ដែលជាអង្គការជួយបង្កើនសមត្ថភាពរបស់យុវជនខ្មែរនៅប្រទេសកម្ពុជា។

Vocabulary
ស្កុត — scout

www.theallpapers.com

Marks

(a) How would you describe Sothea today? **4**

(b) What does Sothea mean when she says 'I changed my attitude completely'? **3**

www.theallpapers.com

Part B (Question 9)
(10 marks)

When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:

- *understand general and specific aspects of a text by identifying, analysing, and responding to information;*
- *convey information coherently (structure, sequence, accuracy and variety of vocabulary and sentence structure) and appropriately (relevance, use of conventions of the text type).*

---

9. Read the text and then answer the question on page 11 in 150 to 200 words in KHMER.

គុណវិបត្តិច្រើនជាងគុណសម្បត្តិ

នៅក្នុងសង្គមសព្វថ្ងៃមានយុវជនភាគច្រើនក៏ដូចជាមនុស្សស្រករមុនមួយចំនួនចូលចិត្តអង្គុយនៅមុខកុំព្យូទ័ររបស់គេអស់រយៈពេលយ៉ាងយូរដើម្បីលេងល្បែងកុំព្យូទ័រ រឺធ្វើការស្រាវជ្រាវក្នុងអ៊ិនធឺរណិត។ អំពើនេះអាចផ្តល់គុណវិបត្តិដល់ខ្លួនអ្នកជាច្រើនយ៉ាង។

តើអ្នកមានលក្ខណៈទាំងឡាយខាងក្រោមនេះទេ?

1. វ៉ិបអាហាល់លិក(Webaholic):
អ្នកមានជំងឺវ៉ិបអាហាល់លិក បើអ្នកប្រើប្រាស់អ៊ិនធឺរណិតកាន់តែច្រើនឡើងៗ។

2. កុំព្យូទ័រ វីស្យុន ស៊ិនដ្រូម Computer Vision Syndrome (CVS):
អ្នកប្រហែលជាឈឺកដៃ ក ខ្នង ស្មានិងឈឺភ្នែកហើយមើលមិនច្បាស់ដោយហេតុមកពីមិនបានទទួលទានអាហារត្រឹមត្រូវនិងទទួលទានដំនេកមិនបានគ្រប់គ្រាន់។

3. ទំលាប់នៃការសិក្សាមានកំរិតទាប:
នេះបណ្តាលមកពីការប្រើប្រាស់ពេលវេលាសិក្សាសំរាប់លេងល្បែងកុំព្យូទ័រ។

4. មិនសូវចូលរួមក្នុងសង្គម:
អ្នកមិនសូវចង់ស្វែងរកមិត្តភក្តិ ហើយចូលចិត្តនៅតែឯងស្ងាត់ៗក្នុងបន្ទប់។

បើសិនជាដូច្នេះមែន អ្នកគួរតែបន្ថយការប្រើប្រាស់អ៊ិនធឺរណិត។ អង្គការយើងអាចផ្តល់សេវាខាងជួយគិតនិងណែនាំដោយឥតគិតថ្លៃ ហើយនិងរក្សាទុកភាពសំងាត់ផង។

សូមទូរស័ព្ទមកអង្គការ វេ ហ្វវរដ (Way Forward) ថ្ងៃនេះតាមទូរស័ព្ទលេខ:៧២៥ ៣៥១ ០៦៧។

www.theallpapers.com

You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.

You may make notes on this page.

www.theallpapers.com

This page is intentionally blank

www.theallpapers.com

Question 9

The Cambodian Association has received this advertisement and is deciding whether or not to include it in its youth newsletter. The association has invited you to give a talk at its next meeting to help it to make a decision. Write the text of your talk, conveying your opinion on each of the views presented in the advertisement.

សមាគមខ្មែរបានទទួលការផ្សាយពាណិជ្ជកម្មខាងលើនេះ ហើយមិនដឹងសំរេចចិត្តថានឹងចុះរឺមិនចុះវាក្នុងព្រឹត្តិប័ត្រយុវជនទេ។ សមាគមខ្មែរបានអញ្ជើញអ្នកអោយមកនិយាយក្នុងសម័យប្រជុំលើកក្រោយដើម្បីជួយដល់ការសំរេចចិត្តរបស់គេ។ ចូរអ្នកសរសេរអត្ថបទសំរាប់និយាយរបស់អ្នក ដោយបញ្ជាក់ពីយោបល់របស់អ្នកចំពោះទស្សន:នីមួយៗដែលមាននៅក្នុងការផ្សាយពាណិជ្ជកម្ម។

www.theallpapers.com

End of Section 2

www.theallpapers.com

Student/Registration Number | | | | | | | | | | |

Centre Number | | | | | | |

2011 PUBLIC EXAMINATION

Khmer

Continuers Level

Section 3: Writing in Khmer (15 marks)

Instructions to Students

1. Allow approximately 45 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet in blue or black ink or ball-point pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2011

www.theallpapers.com

Section 3 (Questions 10 to 11)
(15 marks)

When judging performance in this section, the examiner(s) will take into account the extent to which the student demonstrates:

- *relevance and depth of treatment of ideas, information, or opinions;*
- *accuracy and range of vocabulary and sentence structures;*
- *the capacity to structure and sequence response and capacity to use conventions of the text type.*

Answer ONE question from this section in 200 to 250 words in KHMER.

10. Write the text of a talk that you will give to your class comparing the lifestyle of young Khmer people in Cambodia with the lifestyle of young Khmer people in Australia.

    ចូរអ្នកសរសេរអត្ថបទមួយសំរាប់និយាយក្នុងថ្នាក់របស់អ្នក ដោយធ្វើការប្រៀបធៀបជីវភាពរស់នៅរបស់យុវជនយុវនារីខ្មែរនៅប្រទេសកម្ពុជា ទៅនឹងជីវភាពរស់នៅរបស់យុវជនយុវនារីខ្មែរនៅប្រទេសអូស្ត្រាលី។

11. You and your family went back to visit Cambodia for the first time during the last school holidays. Write an article for your class newsletter reflecting on the significance of this trip.

    អ្នកនិងគ្រួសារអ្នកបានត្រលប់ទៅទស្សនាប្រទេសកម្ពុជាជាលើកទីមួយកាលពីវិស្សមកាលសាលាកន្លងទៅ។ ចូរអ្នកសរសេរអត្ថបទសំរាប់ចុះផ្សាយក្នុងព្រឹត្តិប័ត្រថ្នាក់មួយរបស់អ្នក ដោយឆ្លុះបញ្ចាំងអំពីហេតុការណ៍ដែលគួរអោយចាប់អារម្មណ៍ក្នុងការធ្វើដំនើរនេះ។

www.theallpapers.com

You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.

You may make notes on this page.

www.theallpapers.com

This page is intentionally blank

www.theallpapers.com

Question Number:

www.theallpapers.com

www.theallpapers.com

End of Section 3

www.theallpapers.com